ក

# មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២២-៩-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៩១០/៧៧៤ ស្តីពី ការតែងតាំង ឯកឧត្តម និង លោកជំទាវ ចំនួន ០៣ រូប ជាទីប្រឹក្សា និង ជាជំនួយការសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា ៧៩៤៦

០៤-១០-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១០១០/៧៩០ ស្តីពី ការបញ្ឈប់មុខងារលោកជំទាវ យឹម នៃលីន ពីជំនួយការសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា ៧៩៤៧


## II. រាជរដ្ឋាភិបាល

### សេចក្តីសម្រេច


៣០-៩-២០១០ -សេចក្តីសម្រេចលេខ ៥០ សសរ ស្តីពី ការបង្កើតគណៈកម្មការរៀបចំបុណ្យចំរើនព្រះជន្មវស្សាប្រគេនសម្តេចព្រះវន្ធ័រត ណយ ច្រឹក ព្រះសង្ឃនាយករង ទី ៣ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគម្រប់ ៥៩ យាងចូល ៦០ ព្រះវស្សា និង សម្ពោធហោត្រៃ ព្រមទាំងសមិទ្ធិផលនានាក្នុងវត្តច័ន្ទបូរីវង្ស នៅថ្ងៃទី ១១-១២ ខែធ្នូ ឆ្នាំ ២០១០ ៧៩៤៨

០១-១០-២០១០ -សេចក្តីសម្រេចលេខ ៥១ សសរ ស្តីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៧៩៥០


## III. ការិយាល័យក្រសួង

### ១. ទីស្តីការគ្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៩-៩-២០១០ -ប្រកាសលេខ ៧២៤ សហវ.ប្រក ស្តីពីការបង្កើតក្រុមការងារជំរុញគៀរគរចំណូលពីការជួសជុលទ្រព្យសម្បត្តិរដ្ឋ និង ឯកជនភាវូបនីយកម្ម ៧៩៥១

២៩-៩-២០១០ -ប្រកាសលេខ ៧២៥ សហវ.ប្រក ស្តីពីការបង្កើតក្រុមការងារជំរុញគៀរគរចំណូលពីដីសម្បទានសេដ្ឋកិច្ច ការជួលវិនិយោគកោះសម្បទានលើហេដ្ឋារចនាសម្ព័ន្ធនានា និង ទីតាំងផ្សេងទៀត ៧៩៥៤

២៩-៩-២០១០ -ប្រកាសលេខ ៧២៦ សហវ.ប្រក ស្តីពីការបង្កើតក្រុមការងារជំរុញគៀរគរចំណូលពីវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ លិខិតឆ្លងដែន ទិដ្ឋាការ និង វិស័យអាកាសចរស៊ីវិល ៧៩៥៧

២២-៩-២០១០ -សេចក្តីសម្រេចលេខ ០៣៤ សហវ ស្តីពី ការបង្កើតក្រុមសម្របសម្រួល នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ៧៩៦០

## ២. ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

២០-៨-២០១០ -ប្រកាសលេខ ៥៤៩ ប្រក.កសក ស្តីពី ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ ក្នុងខេត្តកំពត ៧៩៦៣

២០-៨-២០១០ -ប្រកាសលេខ ៥៥០ ប្រក.កសក ស្តីពី ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ ក្នុងខេត្តតាកែវ ៧៩៧០

២០-៨-២០១០ -ប្រកាសលេខ ៥៥១ ប្រក.កសក ស្តីពី ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ ក្នុងខេត្តកំពង់ស្ពឺ ៧៩៧៥

## ៣. ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០១៧៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អី អិម យូ ស៊ី អ៊ិនវេស មេន គ្រុប ៧៩៨៦

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០១៨០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហ្វ៊ិត ៣៨ ៧៩៨៨

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០២០០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន ឆេវ៉ង់ ម៉ាញូលីខ ភីធីអ៊ី.លីមីធីត ៧៩៩០

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០២០១ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការបង្កើត ការិយាល័យតំណាងពាណិជ្ជកម្ម នៃក្រុមហ៊ុន ផូមីណា ស្មឿល ខបនើរសិន (ចុះបញ្ជីនៅប្រទេសវៀតណាម) ប្រចាំព្រះរាជាណាចក្រកម្ពុជា ៧៩៩១

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០២០៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេឡិគទ្រីស៊ីធី ប្រីហ្វេសិនណលសឺវីស ៧៩៩២

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០២១០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស្ទូខេលជ័. ខេ អេច ៧៩៩៤

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០២១១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខ្ញ៉ូខ ចាន់ណា ខនស្ត្រាក់សិន ៧៩៩៦

១២-០១-២០១០ -លិខិតបញ្ជាក់លេខ ០២១២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន សាន់-ហ្វ៊ុលខនសាល់ធេន (គ្រុប) ៧៩៩៨

# ព្រះរាជក្រឹត្យ

នស/រកត/០៩១០/៧៧៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាសិរីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង :

១- ឯកឧត្តម ស្រី សុខុន ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

២- ឯកឧត្តម ធា គីមសុទ្ធ ជាជំនួយការសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

៣- លោកជំទាវ ពេជ្រ ពុទ្ធិសាធបូរ៉ានារី ជាជំនួយការសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ៧. ២០០៩. ៧៤៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១០

លេខ ៧៧០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ១០ ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/១០១០/៧៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានបញ្ឈប់មុខងារលោកជំទាវ **ឃឹម ឆៃលីន** ពីជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១០*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

៣.វ. ១០១០.៩០៥

**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខៈ ៧៧៦ ច.ល
ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ខែ តុលា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនគេន

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥០ .សសរ

## សេចក្តីសម្រេច

### ស្តីពី ការបង្កើតគណៈកម្មការរៀបចំបុណ្យចម្រើនព្រះជន្មវស្សា ប្រគេនសម្តេចព្រះវន្ន័ត ណយ ជ្រីក ព្រះសង្ឃនាយករង ទី៣ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគម្រប់ ៥៩ យាងចូល ៦០ ព្រះវស្សា និង សម្ពោធហោត្រៃ ព្រមទាំងសមិទ្ធផលនានា ក្នុងវត្តចន្ទបូរីវង្ស នៅថ្ងៃទី ១១-១២ ខែធ្នូ ឆ្នាំ ២០១០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីបុណ្យចម្រើនព្រះជន្មវស្សាប្រគេន**សម្តេចព្រះវន្ន័ត ណយ ជ្រីក** និងពិធីសម្ពោធហោត្រៃ ព្រមទាំងសមិទ្ធផលនានា នៅក្នុងវត្តចន្ទបូរីវង្ស ដែលមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- សម្តេចព្រះពោធិវង្ស | **អ៊ំ** | **លឹមហេង** | ប្រធាន |
| ២- ឯកឧត្តម | **មិន** | **ឃិន** | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តមបណ្ឌិត | **ម៉ែន** | **ស៊ីម៉ន** | អនុប្រធាន |
| ៤- ឯកឧត្តម | **កែប** | **ជុតិមា** | អនុប្រធាន |
| ៥- ឯកឧត្តម | **ឈុន** | **ស៊ីរុន** | អនុប្រធាន |
| ៦- សម្តេចព្រះឧត្តមវង្សា | **ម្ចូង** | **រី** | សមាជិក |
| ៧- សម្តេចព្រះមហាអរិយវង្ស | **សៅរ៍** | **ចន្ទថុល្ល** | សមាជិក |
| ៨- ព្រះពុទ្ធិវង្ស | **ជា** | **សំអាង** | សមាជិក |

| | | | |
|---|---|---|---|
| ៩- ព្រះរតនរង្សី | **សាន** | **វិបុល** | សមាជិក |
| ១០- ឯកឧត្តមនាយឧត្តមសេនីយ៍ | **ហ៊ីង** | **ប៊ុនហៀង** | សមាជិក |
| ១១- ឯកឧត្តម | **ហ៊ុន** | **ស៊ីថា** | សមាជិក |
| ១២- ឯកឧត្តម | **យូ** | **ស៊ុនឡុង** | សមាជិក |
| ១៣- ឯកឧត្តម | **ខាំ** | **សុខុម** | សមាជិក |
| ១៤- ឯកឧត្តម | **ឆី** | **សុគន្ធ** | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ចរៀបចំកម្មវិធី និងលើកគម្រោងបថ្ម័យសម្រាប់ដោះស្រាយចំណូល-ចំណាយ ក្នុងការរៀបចំពិធីបុណ្យចម្រើនព្រះជន្មវស្សាប្រគេន**សម្តេចព្រះវន្ន័រ័ត ណាយ ជ្រឹក** និងពិធីសម្ពោធហោត្រៃ ព្រមទាំងសមិទ្ធផលនានានៅក្នុងវត្តច័ន្ទបូរីវង្ស ឱ្យប្រព្រឹត្តទៅបានល្អប្រសើរ ហើយអាចបង្កើតអនុគណៈកម្មការជំនាញ ជាជំនួយការ តាមការចាំបាច់ ។

**ប្រការ ៣ :** សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- សម្តេចព្រះអគ្គមហាសង្ឃរាជ នន្ទ ខ្សេម
- គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងធម្មការ និងសាសនា
- ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- សាលារាជធានីភ្នំពេញ
- សាលាខេត្តកណ្តាល
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៥១ . សសរ

# សេចក្តីសម្រេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### ស ម្រេ ច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអញ្ជើញទៅចូលរួម**កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី ៨** នៅទីក្រុងប្រ៊ុចសែល. ប្រទេសប៊ែលហ្ស៊ិក ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១០ រហូតដល់ពេលសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងឯកឧត្តម **ស ខេង** ត្រូវអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៧២៤ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០១០

# ប្រកាស
# ស្តីពី
# ការបង្កើតក្រុមការងារ
# ជំរុញគៀរគរចំណូលពី ការជួលទ្រព្យសម្បត្តិរដ្ឋ និងឯកជនភាវូបនីយកម្ម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ១៣៤អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារជំរុញកៀរគរចំណូលពី ការជួលទ្រព្យសម្បត្តិរដ្ឋ និងឯកជនភាវូបនីយកម្មដែលមាន សមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ទេព្យ វិសុទ្ធ** | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ហ៊ាន សាហ៊ីប** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៤- លោក **នេត មុន្នី** | ប្រធាន នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៥- លោក **អ៊ុំ ឈាង** | ប្រធាន នាយកដ្ឋានឃ្លាំងបេឡា និងបំណុល អគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៦- លោក **ប៊ុន បុណ្ណារិទ្ធ** | អនុប្រធាន នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៧- លោក **សាន់ សារោ** | អនុប្រធាន នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៨- លោក **អោម ចន** | អនុប្រធាន នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ អគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៩- លោក **នួន សំបូរ** | ប្រធាន ការិយល័យអចលនទ្រព្យ | សមាជិក |
| ១០- លោក **គីម កែវមុនីរ័ត្ន** | ជំនួយការ អគ្គលេខាធិការ | សមាជិក |
| ១១- លោក **ម៉ម រិទ្ធី** | អនុប្រធាន ការិយាល័យអចលនទ្រព្យ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១២- លោក **មុំ ចាន់ណា** | អនុប្រធាន ការិយាល័យអចលនទ្រព្យ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៣- លោក **សុក ការុណោត** | អនុប្រធាន ការិយាល័យអចលនទ្រព្យ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៤- លោក **គីក ប៊ុនរ៉ាស៊ី** | អនុប្រធាន ការិយាល័យអចលនទ្រព្យ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | លេខាធិការ |

**ប្រការ២:** ក្រុមការងារនេះមានតួនាទី និងភារកិច្ចដូចតទៅ:
- ជាសេនាធិការអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការជំរុញតឹងទារបំណុល និងកៀរគរចំណូលពីការជួល ទ្រព្យសម្បត្តិរដ្ឋ និងឯកជនភាវូបនីយកម្ម ។
- ពិនិត្យតាមដាន និងដាក់ចេញវិធានការជាប្រចាំ ដើម្បីជម្រុញតឹងទារបំណុល និងគៀងគរចំណូល ។

- ពិនិត្យទិដ្ឋភាពផ្លូវច្បាប់ ដើម្បីរកលទ្ធភាពសើរើ ឬលប់ កិច្ចសន្យាជួល កិច្ចសន្យាផ្ទេរឯកជនភាវូបនីយកម្ម ដែលមិនបានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌកំណត់ ឬធ្វើអោយរដ្ឋខាតបង់ចំណូល ។
- រាយការណ៍អំពីលទ្ធផលការងារដែលសម្រេចបានជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្នើសុំសេចក្តីសម្រេច និងការណែនាំបន្ថែម ។

**ប្រការ៣:** អនុប្រធាន សមាជិក ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការងារជំនួស ក្នុងករណីមានធុរៈជាយថាហេតុ ។

**ប្រការ៤:** រាល់លិខិតបទដ្ឋានដែលផ្ទុយពីការប្រកាសនេះ ចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ អគ្គាធិការ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវសហការ និងអនុវត្តការងារអោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

*កន្លែងទទួល:*

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួង -ស្ថាប័នពាក់ព័ន្ធ*
- *ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ឯកសារ -កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧២៩ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១០

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារ ជំរុញការប្រមូលចំណូលពី ដីសម្បទានសេដ្ឋកិច្ច ការជួលវិនិយោគលើដី សម្បទានលើហេដ្ឋារចនាសម្ព័ន្ធនានា និងទីតាំងផ្សេងទៀត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ៧៨អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារជំរុញកៀរគរចំណូលពី ដីសម្បទានសេដ្ឋកិច្ច ការជួលវិនិយោគកោះ សម្បទានលើហេដ្ឋារចនាសម្ព័ន្ធនានា និងទីតាំងផ្សេងទៀត ដែលមានសមាសភាព ដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- ឯកឧត្តម **គង់ វិបុល** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **វង្សី វិស្សុត** | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ជូ វិជិត្ត** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៤- លោក **នេត មុន្នី** | ប្រធាន នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៥- លោក **នួន វិទ្យា** | ប្រធាន នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាន អគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៦- លោក **ម៉ិន បុណ្ណារិទ្ធ** | អនុប្រធាន នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៧- លោក **ឆាំង សុផល** | អនុប្រធាន នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៨- លោក **រ័ត្ន មុន្នី** | អនុប្រធាន នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ អគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៩- លោក **អេង ឆូច** | ជំនួយការ អគ្គលេខាធិការ | សមាជិក |
| ១០- លោក **ខិន រិទ្ធី** | ប្រធាន ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១- លោក **គីក ម៉ូរ៉ាស៊ី** | អនុប្រធាន ការិយាល័យអចលនទ្រព្យ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១២- លោកស្រី **សួន ពិនកាន្និកា** | អនុប្រធានការិយាល័យធនធានធម្មជាតិ និងសម្បទាន នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ | លេខាធិការ |

**ប្រការ២:** ក្រុមការងារនេះមានតួនាទី និងភារកិច្ចដូចតទៅៈ

- ជាលេខាធិការអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការជំរុញតឹងទារបំណុល និងចំណូលពីដីសម្បទានសេដ្ឋកិច្ច ការជួលវិនិយោគកោះ សម្បទានលើហេដ្ឋារចនាសម្ព័ន្ធនានា និងទីតាំងផ្សេងទៀត ។
- ពិនិត្យតាមដាន និងដាក់ចេញវិធានការជាប្រចាំ ដើម្បីជម្រុញតឹងទារបំណុល និងចំណូលពីដីសម្បទានសេដ្ឋកិច្ច និងការជួលវិនិយោគកោះ សម្បទានលើហេដ្ឋារចនាសម្ព័ន្ធនានា និងទីតាំងផ្សេងទៀត ។

- ពិនិត្យទិដ្ឋភាពផ្លូវច្បាប់ ដើម្បីរកលទ្ធភាពសើរើ ឬលុបកិច្ចសន្យាវិនិយោគ កិច្ចសន្យាជួល ដែលមិនបានអនុវត្ត ត្រឹមត្រូវតាមលក្ខខណ្ឌកំណត់ ឬធ្វើអោយរដ្ឋខាតបង់ចំណូល ។
- រាយការណ៍អំពីលទ្ធផលការងារដែលសម្រេចបានជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្នើសុំសេចក្តីសម្រេច និងការណែនាំបន្ថែម ។

**ប្រការ៣:** អនុប្រធាន សមាជិក ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំការងារជំនួស ក្នុងករណីមានធុរៈជាយថាហេតុ ។

**ប្រការ៤:** រាល់លិខិតបទដ្ឋានដែលផ្ទុយពីការប្រកាសនេះ ចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ អគ្គាធិការ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវសហការ និងអនុវត្តការងារអោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

***កន្លែងទទួល:***

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួង-ស្ថាប័នពាក់ព័ន្ធ*
- *ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៧២៦ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១០

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារ ជំរុញគៀរគរចំណូលពី វិស័យប្រៃសណីយ៍ ទូរគមនាគមន៍ លិខិតឆ្លងដែន និដ្ឋាការ និងវិស័យអាកាសចរស៊ីវិល

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៨អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្ដីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១**: ត្រូវបានបង្កើតក្រុមការងារកៀរគរចំណូលពី វិស័យប្រៃសណីយ៍ ទូរគមនាគមន៍លិខិតឆ្លងដែន ទិដ្ឋាការ និងវិស័យអាកាសចរស៊ីវិល ដែលមានសមាសភាព ដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ុ ម៉ុនឡុង** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ចន្ទី វិស្សុត** | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ញឹម ខេមរា** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៤- លោក **អ៊ូន ប៊ុនហាក់** | ប្រធាន នាយកដ្ឋាន ចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៥- លោក **ខឹម រិទ្ធីសែន** | ប្រធាន នាយកដ្ឋានចំណូល-ចំណាយថវិកាជាតិ អគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៦- លោក **ចែម វាសនា** | ប្រធាន នាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ អគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៧- លោក **ម៉ែន ទុត្ថា** | អនុប្រធានទី១ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៨- លោក **គុយ សៀ** | ប្រធានការិយាល័យទី៣ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៩- លោក **រស់ ម៉ារឌី** | ប្រធាន ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១០- លោក **ចាន់ ផល** | ប្រធាន ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងមហាផ្ទៃផ្នែកសន្តិសុខសាធារណៈ | សមាជិក |
| ១១- លោកស្រី **សិន ម៉ូលីវណ្ណា** | ប្រធាន ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១២- លោក **ស៊ុនលី ធារិទ្ធ** | ជំនួយការ អគ្គលេខាធិការ | សមាជិក |
| ១៣- លោកស្រី **ហ៊ី សូរីដា** | អនុប្រធានការិយាល័យទី៣ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ១៤- លោក **ពៅ ភក្ត្រា** | អនុប្រធាន ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៥- លោកស្រី **ប្រុក ម៉ុះរឿម** | អនុប្រធានការិយាល័យទី១ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ | លេខាធិការ |

**ប្រការ២:** ក្រុមការងារនេះមានតួនាទី និងភារកិច្ចដូចតទៅ:

- ជាសេនាធិការអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការជំរុញពង្រឹងទារបំណុល និងចំណូលបានមកពី វិស័យប្រៃសណីយ៍ ទូរគមនាគមន៍ លិខិតឆ្លងដែន ទិដ្ឋាការ និងវិស័យអាកាសចរស៊ីវិល ។
- ពិនិត្យតាមដាន និងដាក់ចេញវិធានការជាប្រចាំ ដើម្បីជម្រុញពង្រឹងទារបំណុល និងចំណូលបានមកពី វិស័យប្រៃសណីយ៍ ទូរគមនាគមន៍ លិខិតឆ្លងដែន ទិដ្ឋាការ និងវិស័យអាកាសចរស៊ីវិល ។
- ពិនិត្យទិដ្ឋភាពផ្លូវច្បាប់ ដើម្បីរកលទ្ធភាពសើរើ ឬលប់កិច្ចសន្យាវិនិយោគ និងកិច្ចសន្យាផ្សេងៗ ដែលមិនបានអនុវត្តត្រឹមត្រូវតាមលក្ខខណ្ឌកំណត់ ឬធ្វើអោយរដ្ឋខាតបង់ចំណូល ។
- រាយការណ៍អំពីលទ្ធផលការងារដែលសម្រេចបានជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្នើសុំសេចក្តីសម្រេច និងការណែនាំបន្ថែម ។

**ប្រការ៣:** អនុប្រធាន សមាជិក ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានដើម្បីដឹកនាំការងារជំនួស ក្នុងករណីមានធុរៈជាយថាហេតុ ។

**ប្រការ៤:** រាល់លិខិតបទដ្ឋានដែលផ្ទុយពីការប្រកាសនេះ ចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:** អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ អគ្គាធិការ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវសហការ និងអនុវត្តការងារអោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

*កន្លែងទទួល:*

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួង -ស្ថាប័នពាក់ព័ន្ធ*
- *ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ឯកសារ -កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៧៤ សហវ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមសម្របសម្រួល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧ ស្ដីពីការកែសំរួលការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្ដីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសលេខ ១២០ សហវ ប្រក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្ដីពីការកែសម្រួល ប្រកាសលេខ ២១៨ សហវ ប្រក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការបង្កើតគណៈកម្មាធិការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងលើភាពចាំបាច់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# សម្រេច

**ប្រការ ១.-**

បង្កើត **«ក្រុមសម្របសម្រួល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ»** ហៅកាត់ **«កសហ»** ដែលមានភារកិច្ចសម្របសម្រួលបច្ចេកទេសផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសេនាធិការបច្ចេកទេសរបស់គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**ប្រការ ២.-**

**«កសហ»** មាន ៥ ក្រុម ដែលដឹកនាំដោយអគ្គលេខាធិការ ឬអគ្គលេខាធិការរងមួយរូប និងមានសមាសភាពដូចខាងក្រោម ÷

**១-ក្រុមរៀបចំថវិកា**: ដឹកនាំដោយឯកឧត្តម **ទង់ សណ្តាប់** អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នាយកដ្ឋាន ដែលត្រូវសម្របសម្រួលរួមមានៈ នាយកដ្ឋានថវិកា នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការអន្តរជាតិ និងនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ។

**២-ក្រុមចំណូល**: ដឹកនាំដោយឯកឧត្តម **ជូ វិជិត្ត** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អគ្គនាយកដ្ឋាន និងនាយកដ្ឋាន ដែលត្រូវសម្របសម្រួលរួមមានៈ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ។

**៣-ក្រុមអនុវត្តថវិកា**: ដឹកនាំដោយឯកឧត្តម **ញ៉ឹម ខេមរា** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាព ដែលត្រូវសម្របសម្រួលរួមមានៈ អគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានលទ្ធកម្មសាធារណៈ និងអង្គភាពគ្រប់គ្រងសាច់ប្រាក់ ។

**៤-ក្រុមគោលនយោបាយ**: ដឹកនាំដោយឯកឧត្តម **រស់ សីលវ៉ា** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នាយកដ្ឋាន និងអង្គភាព ដែលត្រូវសម្របសម្រួលរួមមានៈ នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នាយកដ្ឋាននីតិកម្ម នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន អគ្គាធិការដ្ឋាន និងនាយកដ្ឋានព័ត៌មានវិទ្យា។

**៥-ក្រុមគាំទ្រ**: ដឹកនាំដោយឯកឧត្តម **ហ៊ាន សាហ៊ីប** អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នាយកដ្ឋាន និងអង្គភាព ដែលត្រូវសម្របសម្រួលរួមមានៈ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាយកដ្ឋានសវនកម្មផ្ទៃក្នុង ។

**ប្រការ ៣.-**

**«គសហ»** មានភារកិច្ចសម្របសម្រួលបច្ចេកទេស លើការអនុវត្តផែនការសកម្មភាពការងារនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល ពិសេសគឺមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការដឹកនាំ និងសម្របសម្រួលការអនុវត្តផែនការសកម្មភាពការងាររបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និង អង្គភាពដែលស្ថិតក្នុងក្រុមការងារនីមួយៗដូចមានចែងក្នុងប្រការ ២ ក្នុងនាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្នុងនាមគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របតាមលក្ខខណ្ឌយោងនៃក្រុមសម្របសម្រួលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ ។

**ប្រការ ៤.-**

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១០

គាត ឈន់

**ចំលងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង- ស្ថាប័ន
- គ្រប់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាព ចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាមីខ្លួន ដើម្បីអនុវត្ត
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៤៩ ប្រក.កសក

លិខិតចូល
ថ្ងៃទី.០៣...ខែ.១០...ឆ្នាំ20១០

# ប្រកាស
## ស្តីពី
## ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពត

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ... ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Sangkat Tonle Basak Khan Chamkamon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

- បានឃើញប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

### ប្រការ ១.-

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពត សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តភាពតាមលក្ខណៈសហគមន៍ព្រៃឈើ ដែលមានទីតាំងស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើឈូក នៃខណ្ឌរដ្ឋបាលព្រៃឈើកំពត ។

### ប្រការ ២.-

ការបង្កើតតំបន់ព្រៃសហគមន៍ក្នុងគោលបំណង :

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្ស និង អភិវឌ្ឍព្រៃសហគមន៍ឱ្យមាននិរន្តភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើ ជាលក្ខណៈប្រពៃណី សម្រាប់ការរស់នៅ ទំនៀមទម្លាប់ និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមសក្តានុពល និង លទ្ធភាពធនធានព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

### ប្រការ ៣.-

តំបន់ព្រៃសហគមន៍ក្នុងខេត្តកំពតនៃប្រកាសនេះមាន ០៨ សហគមន៍ព្រៃឈើ ចែកចេញជា ១០ កន្លែង ដែលមានផ្ទៃដីសរុបចំនួន ៣.៨១៥ (បីពាន់ប្រាំបីរយដប់ប្រាំ) ហិកតា ដូចមានក្នុងផែនទីទីតាំងព្រៃសហគមន៍ និង ផែនទីសហគមន៍នីមួយៗភ្ជាប់ជាឧបសម្ព័ន្ធ១ នៃប្រកាសនេះ និងជាប្រព័ន្ធខ្សែព្រំបិទជិត កំណត់ដោយចំណុចគោល និងនិយាមកា ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។

### ប្រការ ៤.-

ដំណើរការរៀបចំនិងការប្រព្រឹត្តិទៅនៃសហគមន៍ព្រៃឈើនៅក្នុងតំបន់ព្រៃសហគមន៍ដែលបានកំណត់ក្នុងប្រកាសនេះត្រូវអនុវត្តតាមនីតិវិធី ដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។

### ប្រការ ៥.-

ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦.–

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយដ្ឋានផែនការនិងស្ថិតិ ប្រធានមន្ទីរកសិកម្មខេត្តកំពត និង ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី...២១...ខែ...មីនា...ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ចាន់ សារុន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តកំពត
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ


1160000
1180000
1200000
1220000
400000
420000
440000
460000
480000
Coordinate Systems
Zone 48P
Projection: UTM
Map Datum: Indian 1960
1:370,000
0
10
20

ឧបសម្ព័ន្ធ ២ : ភ្ជាប់ប្រកាសលេខ ៥៤៤.... ចុះថ្ងៃទី ១១ ខែ ...សីហា.... ឆ្នាំ ២០១០....

## ទីតាំងព្រៃសហគមន៍ក្នុងខេត្តកំពត

| លរ | ឈ្មោះសហគមន៍ | ផ្ទៃដី (ហិកតា) | និយាមកា UTM កំណត់បណ្តាញប្រព័ន្ធពិភាគ ឥណ្ឌា ១៩៦០ | | | | | | | ភូមិ | ឃុំ | ស្រុក | ផ្នែករដ្ឋបាល ព្រៃឈើ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ភ្នំចងឯក | ៦៩ | កើត | A | 416971 | 1213842 | B | 416632 | 1213084 | ១ | តាកែន | ឈូក | ឈូក |
| | | | ត្បូង | B | 416632 | 1213084 | C | 416032 | 1213488 | | | | |
| | | | លិច | C | 416032 | 1213488 | D | 416267 | 1214298 | | | | |
| | | | ជើង | D | 416267 | 1214298 | E | 416555 | 1214216 | | | | |
| | | | | E | 416555 | 1214216 | A | 416971 | 1213842 | | | | |
| ២ | ស្រែលាវ | ៣១ | កើត | A | 420269 | 1200463 | B | 420356 | 1200137 | ១ | ត្រពាំងភ្លាំង | ឈូក | ឈូក |
| | | | ត្បូង | B | 420356 | 1200137 | C | 419876 | 1200035 | | | | |
| | | | | C | 419876 | 1200035 | D | 419704 | 1200133 | | | | |
| | | | លិច | D | 419704 | 1200133 | E | 419682 | 1200505 | | | | |
| | | | ជើង | E | ‘419682 | 1200505 | A | 420269 | 1200463 | | | | |
| ៣ | ព្រៃខ្មៅ | ១៩៧ | កើត | A | 445107 | 1211881 | B | 445679 | 1211456 | ១ | ស្រែក្នុង | ជុំគិរី | ឈូក |
| | | | | B | 445679 | 1211456 | C | 446335 | 1210430 | | | | |
| | | | ត្បូង | C | 446335 | 1210430 | D | 444174 | 1210468 | | | | |
| | | | លិច | D | 444174 | 1210468 | E | 444 773 | 1211642 | | | | |
| | | | ជើង | E | 444 773 | 1211642 | A | 445107 | 1211881 | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤ | ត្រពាំងស្តៅ ផ្ទៃដី៣៤១ | ២៥៣ | កើត | A | 420057 | 1199876 | B | 422150 | 1198327 | ១ | ត្រពាំងភ្លាំង | ឈូក | ឈូក |
| | | | ត្បូង | B | 422150 | 1198327 | C | 421914 | 1198051 | | | | |
| | | | លិច | C | 421914 | 1198051 | D | 418925 | 1198901 | | | | |
| | | | ជើង | D | 418925 | 1198901 | E | 418695 | 1199814 | | | | |
| | | | | E | 418695 | 1199814 | A | 420057 | 1199876 | | | | |
| | | ៨៨ | កើត | A1 | 417628 | 1199363 | B1 | 417219 | 1198624 | | | | |
| | | | ត្បូង | B1 | 417219 | 1198624 | C1 | 416561 | 1199062 | | | | |
| | | | លិច | C1 | 416561 | 1199062 | D1 | 417006 | 1199864 | | | | |
| | | | ជើង | D1 | 417006 | 1199864 | A1 | 417628 | 1199363 | | | | |
| ៥ | ថ្មសរវូងខ្លា | ៩៩០ | កើត | A | 446657 | 1220241 | B | 446658 | 1217498 | ៣ | ស្រែចែង | ជុំគិរី | ឈូក |
| | | | ត្បូង | B | 446658 | 1217498 | C | 444484 | 1218143 | | | | |
| | | | លិច | C | 444484 | 1218143 | D | 444170 | 1218592 | | | | |
| | | | ជើង | D | 444170 | 1218592 | E | 444935 | 1220583 | | | | |
| | | | | E | 444935 | 1220583 | A | 446657 | 1220241 | | | | |
| ៦ | ដំណាក់អ្នកតាថ្មពួន ផ្ទៃដី៩៨៥ | ៨១៨ | កើត | A | 445882 | 1218146 | B | 446451 | 1217277 | ៣ | ស្រែក្នុង | ជុំគិរី | ឈូក |
| | | | | B | 446451 | 1217277 | C | 445590 | 1214204 | | | | |
| | | | ត្បូង | C | 445590 | 1214204 | D | 444679 | 1212672 | | | | |
| | | | | D | 444679 | 1212672 | E | 444493 | 1212693 | | | | |
| | | | លិច | E | 444493 | 1212693 | F | 444248 | 1218142 | | | | |
| | | | ជើង | F | 444248 | 1218142 | A | 445882 | 1218146 | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១៦៧ | កើត | A1 | 446389 | 1214929 | B1 | 446423 | 1212824 | | | | |
| | | | ត្បូង | B1 | 446423 | 1212824 | C1 | 445153 | 1213029 | | | | |
| | | | លិច | C1 | 445153 | 1213029 | D1 | 446012 | 1214653 | | | | |
| | | | ជើង | D1 | 446012 | 1214653 | A1 | 446389 | 1214929 | | | | |
| ៧ | ដំណាក់រលោះ បវរថ្មធំ | ៥៨៧ | កើត | A | 446335 | 1210430 | B | 445827 | 1208501 | ៥ | ស្រែសំរោង | ជុំគិរី | ឈូក |
| | | | | B | 445827 | 1208501 | C | 445610 | 1207170 | | | | |
| | | | ត្បូង | C | 445610 | 1207170 | D | 445229 | 1206765 | | | | |
| | | | លិច | D | 445229 | 1206765 | E | 444756 | 1206815 | | | | |
| | | | | E | 444756 | 1206815 | F | 443893 | 1208833 | | | | |
| | | | ជើង | F | 443893 | 1208833 | G | 444174 | 1210469 | | | | |
| | | | | G | 444174 | 1210469 | A | 446335 | 1210430 | | | | |
| ៨ | ភ្នំធំចំណេងសាមគ្គី | ១០១៥ | កើត | A | 429577 | 1208547 | B | 429448 | 1206519 | ១ | តាកែន | ឈូក | ឈូក |
| | | | ត្បូង | B | 429448 | 1206519 | C | 427898 | 1206904 | | | | |
| | | | លិច | C | 427898 | 1206904 | D | 424934 | 1209866 | | | | |
| | | | ជើង | D | 424934 | 1209866 | E | 424876 | 1210385 | | | | |
| | | | | E | 424876 | 1210385 | F | 426592 | 1210826 | | | | |
| | | | | F | 426592 | 1210826 | G | 427727 | 1210408 | | | | |
| | | | | G | 427727 | 1210408 | A | 429577 | 1208547 | | | | |
| | សរុប | ៣៨១៥ | | | | | | | | ១៦ | ៥ | ២ | ១ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៥០......... ប្រក.កសក

លិខិតចូល

ថ្ងៃទី១៣...ខែតុលា..ឆ្នាំ២០១០

# ប្រកាស

## ស្តីពី

## ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តតាកែវ

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ សហគ្រាសស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
